**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ . ៦៧ . អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាលសិក្សាធិការនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៩/០០៧ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ២៥៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍/.

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ ..**

អនុក្រឹត្យនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍កម្ពុជាដែលសរសេរជាអក្សរកាត់ថា "**ក.ផ.ផ.**" ដើម្បីសិក្សាទីផ្សារនិងផ្សព្វផ្សាយវិស័យទេសចរណ៍នៃព្រះរាជាណាចក្រកម្ពុជា តាមរយៈការពង្រឹងនិងពង្រីកវិសាលភាពនៃការផ្សព្វផ្សាយវិស័យទេសចរណ៍កម្ពុជា និងការជំរុញកិច្ចសហការភាពជាដៃគូនិងការចូលរួមរវាងផ្នែកឯកជននិងផ្នែកសាធារណៈក្នុងការផ្សព្វផ្សាយពីទេសចរណ៍កម្ពុជាទៅកាន់ទីផ្សារទេសចរណ៍អន្តរជាតិ។

## ជំពូកទី២
## តួនាទីនិងភារកិច្ច

**មាត្រា២ ..**

**ក.ផ.ផ.** មានតួនាទីនិងភារកិច្ច ដូចខាងក្រោម៖

- សិក្សាទីផ្សារនិងផ្សព្វផ្សាយវិស័យទេសចរណ៍ទៅកាន់ទីផ្សារអន្តរជាតិ
- ចូលរួមប្រឹក្សាយោបល់លើការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រផ្សព្វផ្សាយនិងទាក់ទាញទេសចរណ៍កម្ពុជា និងចូលរួមអនុវត្តផែនការ
- ពង្រឹងការចូលរួមគាំទ្រពីប្រភពនានា ពិសេសពីផ្នែកឯកជនលើការងារផ្សព្វផ្សាយទេសចរណ៍ក្រៅប្រទេស
- ចូលរួមប្រឹក្សារៀបចំផែនការសកម្មភាពអនុវត្តយុទ្ធសាស្ត្រទីផ្សារទេសចរណ៍កម្ពុជា
- សម្របសម្រួលការផ្សព្វផ្សាយទាក់ទងនឹងវិស័យទេសចរណ៍ដែលធ្វើឡើងដោយផ្នែកឯកជននិងផ្នែកសាធារណៈ
- អនុវត្តសកម្មភាពផ្សេងៗតាមការចាំបាច់ដើម្បីបំពេញរាល់តួនាទីនិងភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

## ជំពូកទី៣
## ក្រុមប្រឹក្សាភិបាលនិងសមាជិកភាព

**មាត្រា៣ ..**

**ក.ផ.ផ.** ត្រូវដឹកនាំដោយរដ្ឋមន្ត្រីក្រសួងទេសចរណ៍ដែលជាប្រធានក្រុមប្រឹក្សាភិបាល។

សមាសភាពរបស់ **ក.ផ.ផ.** ត្រូវមានការចូលរួមក្នុងលក្ខណៈជាដៃគូរវាងផ្នែកឯកជននិងផ្នែកសាធារណៈ។

សមាសភាពជាក់ស្តែងរបស់ **ក.ផ.ផ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលតាមការស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍។

**មាត្រា៤ ..**

**ក.ផ.ផ.** ត្រូវមានសមាជិក១៥(ដប់ប្រាំ)រូប ក្នុងនេះ៨(ប្រាំបី)រូបជាតំណាងមកពីផ្នែកសាធារណៈនិង៧(ប្រាំពីរ)រូបជាតំណាងមកពីផ្នែកឯកជន។ សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ត្រូវតែជារូបវន្តបុគ្គល។ សមាជិកក្រុមប្រឹក្សាភិបាល មានអាណត្តិ៥(ប្រាំ)ឆ្នាំ និងអាចបន្តបានតែ១(មួយ)អាណត្តិប៉ុណ្ណោះ។

រាល់សេចក្តីសម្រេចទាំងអស់របស់ **ក.ផ.ផ.** ត្រូវអនុម័តយល់ព្រមដោយការបោះឆ្នោតយកតាមសំឡេងភាគច្រើនដាច់ខាត របស់សមាជិកក្រុមប្រឹក្សាដែលមានវត្តមាន លើកលែងតែអនុក្រឹត្យឬលក្ខន្តិកៈមានចែងផ្សេងពីនេះ។

**មាត្រា៥ .-**

ប្រធានក្រុមប្រឹក្សាភិបាលមានសំឡេងឧត្តមានុភាពសម្រេចក្នុងករណីមានសំឡេងស្មើគ្នាក្នុងកិច្ចប្រជុំក្រុមប្រឹក្សាភិបាល។

ករណីសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់មកពីផ្នែកសាធារណៈចាកចេញពីតំណែង ឬស្លាប់ ឬអសមត្ថភាព ឬសុំលាលែងនៅក្នុងអាណត្តិរបស់ខ្លួន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ត្រូវស្នើសុំទៅរាជរដ្ឋាភិបាលដើម្បីតែងតាំងសមាជិកថ្មីជំនួសសមាជិកនោះក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរ។

**មាត្រា៦ .-**

សមាជិក៧(ប្រាំពីរ)រូបក្នុងចំណោមសមាជិក១៥(ដប់ប្រាំ)រូបនៅក្នុងក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសពីផ្នែកឯកជនដែលតំណាងឲ្យឧស្សាហកម្មទេសចរណ៍នៅកម្ពុជា។ ដើម្បីធានានូវការសហការភាពជាដៃគូរវាងផ្នែកឯកជននិងផ្នែកសាធារណៈឲ្យបានរឹងមាំ អ្នកតំណាងមកពីផ្នែកឯកជនដែលសំខាន់បំផុតនៅក្នុងឧស្សាហកម្មទេសចរណ៍កម្ពុជា អាចត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលនៅក្នុង **ក.ផ.ផ.** ដូចមានចែងនៅក្នុងអនុក្រឹត្យនេះ។

បន្ទាប់ពីអាណត្តិដំបូងត្រូវបានបញ្ចប់ សមាជិកដែលមកពីផ្នែកឯកជននឹងត្រូវបានជ្រើសរើសតាមនីតិវិធីមួយដែលបើកចំហនិងមានលក្ខណៈប្រកួតប្រជែងស្របតាមលក្ខន្តិកៈ។

លក្ខណសម្បត្តិនិងការជ្រើសរើសបេក្ខភាពពីផ្នែកឯកជននឹងត្រូវកំណត់ក្នុងលក្ខន្តិកៈរបស់ **ក.ផ.ផ.**។ បេក្ខភាពដែលត្រូវបានជ្រើសរើសពីផ្នែកឯកជនជាសមាជិកក្រុមប្រឹក្សាភិបាលមិនអាចត្រូវបានត្រួតពិនិត្យឬបដិសេធឡើយ។

សមាជិកក្រុមប្រឹក្សាភិបាលផ្នែកឯកជននឹងត្រូវផ្លាស់ប្តូរចេញ ប្រសិនបើ៖

- អង្គភាពរបស់សមាជិកក្រុមប្រឹក្សាភិបាលរូបនោះ ត្រូវបានរំលាយ
- មានការបោះឆ្នោតដោយសំឡេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាភិបាលផ្នែកឯកជនទាំងអស់ដោយមានការយល់ព្រមពីប្រធានក្រុមប្រឹក្សាភិបាល ហើយមានមូលហេតុបញ្ជាក់ជាលាយលក្ខណ៍អក្សរ
- មូលហេតុផ្សេងទៀតដែលកំណត់ក្នុងលក្ខន្តិកៈរបស់ **ក.ផ.ផ.**។

លក្ខខណ្ឌនិងនីតិវិធីនៃការជំនួសសមាជិកក្រុមប្រឹក្សាភិបាលផ្នែកឯកជនដែលត្រូវបានផ្លាស់ចេញនឹងត្រូវកំណត់ដោយលក្ខន្តិកៈរបស់ **ក.ផ.ផ.**។

## ជំពូកទី៤
## ការប្រព្រឹត្តទៅរបស់ ក.ផ.ផ.

**មាត្រា៧ .-**

**ក.ផ.ផ.** បើកកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន ឬតំណាងដែលជាសមាជិកក្រុមប្រឹក្សាភិបាល។

**មាត្រា៨ ..**

**គ.ផ.ផ.** អាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ មន្ត្រីជំនាញ អ្នកឯកទេស ឬផ្នែកឯកជនឲ្យចូលរួមប្រជុំពិគ្រោះ ពិភាក្សា ផ្តល់យោបល់ និងសិក្សាស្រាវជ្រាវលើរាល់បញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងក្នុងក្របខណ្ឌការងាររបស់ខ្លួន។

**មាត្រា៩ ..**

បែបបទនិងនីតិវិធីអនុវត្តការងាររបស់ **គ.ផ.ផ.** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុងនិង/ឬលក្ខន្តិកៈរបស់ **គ.ផ.ផ.**។

**មាត្រា១០ ..**

**គ.ផ.ផ.** អាចបង្កើតក្រុមការងារជំនាញមួយចំនួនតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃកិច្ចដំណើរការរបស់ខ្លួន។ តួនាទីនិងភារកិច្ចក្រុមការងារជំនាញនីមួយៗ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ផ.ផ.**។

**មាត្រា១១ ..**

**គ.ផ.ផ.** អាចទទួលយកទីប្រឹក្សាបច្ចេកទេសនិងអ្នកជំនាញជាតិឬអន្តរជាតិនានាមួយចំនួនតាមការចាំបាច់។

**មាត្រា១២ ..**

**គ.ផ.ផ.** មាននាយកដ្ឋានសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍ក្រៅប្រទេស ជាលេខាធិការដ្ឋានដើម្បីបំពេញការងារប្រចាំថ្ងៃនិងសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រទាំងអស់របស់ **គ.ផ.ផ.** និងផ្តល់យោបល់ដល់ក្រុមប្រឹក្សាភិបាល។

តួនាទីនិងភារកិច្ចរបស់លេខាធិការដ្ឋាននៃ **គ.ផ.ផ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធាន **គ.ផ.ផ.**។

**មាត្រា១៣ ..**

**គ.ផ.ផ.** មានសិទ្ធិប្រើត្រារបស់ក្រសួងទេសចរណ៍ ក្នុងកិច្ចដំណើរការការងារប្រចាំថ្ងៃរបស់ខ្លួន។

## ជំពូកទី៥
## លក្ខន្តិកៈរបស់ គ.ផ.ផ.

**មាត្រា១៤ ..**

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវរៀបចំលក្ខន្តិកៈនៅក្នុងកិច្ចប្រជុំលើកទី១របស់ខ្លួន។ លក្ខន្តិកៈនឹងចូលជាធរមាន ក្រោយពីបានទទួលការបោះឆ្នោតយល់ព្រមដោយសំឡេង២ភាគ៣នៃសមាជិកចូលរួមក្នុងអង្គប្រជុំលើកទី១របស់ **គ.ផ.ផ.**។

លក្ខន្តិកៈនេះអាចធ្វើការកែសម្រួលដោយសំឡេងគាំទ្រ២ភាគ៣នៃសមាជិកចូលរួម។

**មាត្រា១៥ ..**

**គ.ផ.ផ.** ត្រូវអនុម័តនីតិវិធីជាលាយលក្ខណ៍អក្សរដើម្បីកំណត់នូវបៀវត្ស លាភការ ថ្លៃបំពេញការងារ និងការចំណាយផ្សេងៗ។

ផ្នែកឯកជនជាអ្នកធានាចំណាយសម្រាប់បៀវត្សរបស់ទីប្រឹក្សា ព្រមទាំងបុគ្គលិកមកពីផ្នែកឯកជនដែលបម្រើការក្នុងផ្នែកជំនាញដែលចំណុះឲ្យលេខាធិការដ្ឋាន។

## ជំពូកទី៦
## ប្រភពធនធានរបស់ គ.ជ.ជ.

**មាត្រា១៦ ..**

ធនធាននិងថវិកាសម្រាប់គាំទ្រដល់ដំណើរការ **គ.ជ.ជ.** មានប្រភពមកពី៖

- ថវិការដ្ឋនៅក្នុងក្របខណ្ឌថវិកាប្រចាំឆ្នាំរបស់ក្រសួងទេសចរណ៍
- ធនធាននិងថវិកាដែលជាការចូលរួមរបស់វិស័យឯកជន
- ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍ
- ប្រភពស្របច្បាប់ផ្សេងៗទៀត។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៧ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៨ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។/.

ថ្ងៃពុធ ៣ រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ឧសភា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**ថោង ខុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទការល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទការល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ